ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៦ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណង ធានាសុវត្ថិភាព នីត្យានុកូលភាព នៃការគ្រប់គ្រងនិងការអភិវឌ្ឍ ប្រកបដោយសង្គតិភាពនិងចីរភាព នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃ “ក្រុមប្រឹក្សានីតិកម្ម” នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងដោយមាត្រា៤ ថ្មី នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពលើរាល់ការងារនីតិកម្ម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ជំពូកទី២**

**មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ**

**មាត្រា៤.-**

ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមុខងារនិងភារកិច្ច ដូចតទៅ៖

- ធានាសង្គតិភាពរវាងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសង្គតិភាពជាមួយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត
- ធានាភាពរលូននិងប្រសិទ្ធភាព ក្នុងការបកស្រាយនិងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ពិនិត្យនិងសម្រេចលើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងសេចក្តីព្រាងវិសោធនកម្មបទប្បញ្ញត្តិទាំងឡាយ ក្រៅពីបទប្បញ្ញត្តិដែលត្រូវធ្វើឡើងជាប្រចាំនិងទៀងទាត់ នៅក្នុងសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើសំណើបកស្រាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធានាការផ្សព្វផ្សាយនិងបង្កើនប្រសិទ្ធភាព នៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាសំខាន់ៗ ដែលមានវេទយិតភាពខ្ពស់ ឬដែលមិនមែនជាកិច្ចសន្យាដែលត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌការងារប្រចាំថ្ងៃ នៅក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើការដោះស្រាយបណ្តឹង ឬវិវាទនានា ដែលជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើសំណើចាត់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការការពារផលប្រយោជន៍ផ្លូវច្បាប់របស់ក្រសួង ជាមួយស្ថាប័នពាក់ព័ន្ធនានា
- ពិនិត្យនិងសម្រេចដាក់ឱ្យប្រើជាផ្លូវការនូវឧបករណ៍ការងារនីតិកម្ម ពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចាត់ចែងឱ្យមានការចូលរួម ពិនិត្យ និងពិភាក្សាជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬក្នុងកិច្ចប្រជុំអន្តរក្រសួង លើការងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

**មាត្រា៥.-**

ក្រុមប្រឹក្សានីតិកម្ម មានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| - ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជារដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ០១ រូប | អនុប្រធានប្រចាំការ |
| - អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម | សមាជិកអចិន្ត្រៃយ៍។ |

## ជំពូកទី៣

## កិច្ចដំណើរការ

**មាត្រា៦.-**

អនុប្រធាននិងសមាជិក នៃក្រុមប្រឹក្សានីតិកម្ម ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន។

ក្នុងករណីអវត្តមាន ឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានជារដ្ឋលេខាធិការមួយរូប ឬ អនុប្រធានប្រចាំការ ឱ្យកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំ តាមការចាំបាច់។

ក្រុមប្រឹក្សានីតិកម្ម មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញការងាររបស់ខ្លួន។

**មាត្រា៧.-**

ដើម្បីធានាប្រសិទ្ធភាពការងារ អនុប្រធានប្រចាំការ និង/ឬ ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ត្រូវទទួលបន្ទុកដឹកនាំនិងសម្របសម្រួលក្រុមការងារ ជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ តាមឋានានុក្រម ក្នុងការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម។

អនុប្រធានប្រចាំការ ត្រូវទទួលបន្ទុកធានាប្រក្រតីភាពនិងនិរន្តរភាពនៃកិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សានីតិកម្ម និងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ប្រកបដោយប្រសិទ្ធភាពនិងសុខដុមភាព។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសប្រគល់ភារកិច្ចដល់ថ្នាក់ដឹកនាំ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជារដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ មួយរូប ឱ្យទទួលបន្ទុកជាអនុប្រធានប្រចាំការ នៃក្រុមប្រឹក្សានីតិកម្ម។

## ជំពូកទី៤
## លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម

**មាត្រា៨.-**

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានលេខាធិការដ្ឋានមួយ មានឋានៈស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួន។

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ដឹកនាំដោយប្រធានមួយរូប មានឋានៈនិងបុព្វសិទ្ធិស្មើអគ្គនាយក ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ អមដោយអនុប្រធានមួយចំនួន មានឋានៈនិងបុព្វសិទ្ធិស្មើអគ្គនាយករង ដែលត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា៩.-**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ត្រូវបំពេញមុខងារនិងភារកិច្ច ដូចខាងក្រោម÷

- ធ្វើជាសេនាធិការបច្ចេកទេសច្បាប់និងរដ្ឋបាល ជូនក្រុមប្រឹក្សានីតិកម្ម
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម
- ផ្តល់ប្រឹក្សាច្បាប់ និងការគាំទ្រផ្នែកច្បាប់ ដល់ថ្នាក់ដឹកនាំនិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត តាមការស្នើសុំ ឬតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម
- ដឹកនាំសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម
- លើកសំណើអំពីការបកស្រាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- ធ្វើកំណត់ហេតុ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម
- បូកសរុបរបាយការណ៍ស្តីពីការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងសេចក្តីព្រាងវិសោធនកម្មពាក់ព័ន្ធ សម្រាប់ដាក់ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច

- ប្រមូលសរុបរបាយការណ៍ស្តីពីការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ដាក់ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងវាយតម្លៃ ឬចាត់វិធានការបន្ត
- ប្រមូលសរុបរបាយការណ៍ស្តីពីខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាសំខាន់ៗ ជូនប្រធានក្រុមប្រឹក្សានីតិកម្មពិនិត្យនិងសម្រេច
- លើកសំណើនិងផ្តល់អនុសាសន៍លើដំណោះស្រាយចំពោះពាក្យបណ្តឹង ឬវិវាទនានា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- លើកសំណើចាត់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការការពារផលប្រយោជន៍ផ្លូវច្បាប់របស់ក្រសួង ជាមួយស្ថាប័នពាក់ព័ន្ធនានា ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- បង្កើតឧបករណ៍ការងារនីតិកម្ម ពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនប្រធានក្រុមប្រឹក្សានីតិកម្មពិនិត្យនិងសម្រេចដាក់ឱ្យប្រើជាផ្លូវការ
- ផ្សព្វផ្សាយកម្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យជំនាញ កម្រងលិខិតរដ្ឋបាលគំរូ និងកម្រងកិច្ចសន្យាគំរូ ដែលត្រូវបានសម្រេចដាក់ឱ្យអនុវត្តជាផ្លូវការដោយក្រុមប្រឹក្សានីតិកម្ម
- រៀបចំឬសម្របសម្រួលការរៀបចំ និងផ្សព្វផ្សាយព្រឹត្តិបត្រ ទិនានុប្បវត្តិ និងមគ្គុទេសក៍នានា ពាក់ព័ន្ធច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម
- រៀបចំនិងដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យានីតិកម្មនានា តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម
- ចូលរួមពិនិត្យនិងពិភាក្សាជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ឬក្នុងកិច្ចប្រជុំអន្តរក្រសួង លើការងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ តាមការចាត់តាំងរបស់ក្រុមប្រឹក្សានីតិកម្ម
- តម្កល់អត្ថបទគតិយុត្ត នៅក្នុងមជ្ឈមណ្ឌលឯកសារច្បាប់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារច្បាប់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម។

**មាត្រា១០.-**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

១- ផ្នែកគាំទ្រទូទៅ

២- ផ្នែកនីតិកម្មចំណូល

៣- ផ្នែកនីតិកម្មចំណាយ

៤- ផ្នែកបច្ចេកវិទ្យាព័ត៌មាននីតិកម្ម។

ផ្នែកនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប មានឋានៈនិងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងដោយអនុក្រឹត្យ អមដោយអនុប្រធានមួយចំនួន មានឋានៈនិងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងដោយប្រកាស។

អង្គការលេខ នៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

**មាត្រា១១.-**

ផ្នែកគាំទ្រទូទៅ បំពេញមុខងារជាសេនាធិការឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម លើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងគាំទ្រទូទៅ។

ផ្នែកនីតិកម្មចំណូល បំពេញមុខងារជាសេនាធិការឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម លើការងារនីតិកម្មផ្នែកចំណូល។

ផ្នែកនីតិកម្មចំណាយ បំពេញមុខងារជាសេនាធិការឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម លើការងារនីតិកម្មផ្នែកចំណាយ។

ផ្នែកបច្ចេកវិទ្យាព័ត៌មាននីតិកម្ម បំពេញមុខងារជាសេនាធិការឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម លើការងារបច្ចេកវិទ្យាព័ត៌មាននីតិកម្ម។

ការរៀបចំនិងការប្រព្រឹត្តទៅ នៃផ្នែក និងអង្គភាពក្រោមឱវាទលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២.-**

អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា១៣.-**

ត្រូវបានធ្វើសមាហរណកម្មនាយកដ្ឋាននីតិកម្ម នៃអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មកក្នុងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

កិច្ចដំណើរការ នៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ត្រូវបន្តនិរន្តរភាពរបស់ខ្លួន ដោយអនុលោមតាមអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៤.-**

ត្រូវបានលុបបទប្បញ្ញត្តិមួយចំនួន នៃអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

- វាក្យខណ្ឌចុងក្រោយ នៃកថាខ័ណ្ឌទី៣ នៃមាត្រា៤ ថ្មី
- ចំណុចទី៣ នៃមាត្រា១២ ថ្មី
- កថាខ័ណ្ឌទី៣ នៃមាត្រា១៣ ថ្មី។

ត្រូវបានលុបបទប្បញ្ញត្តិមួយចំនួន នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

- ពាក្យ "នីតិកម្ម" នៅត្រង់ទី៣ នៃមាត្រា១០
- ត្រង់ទី៨, ត្រង់ទី៩ និងត្រង់ទី១០ នៃមាត្រា១១។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ..៧៦.អនក្រ.បក
ចុះថ្ងៃទី..១៣...ខែ..មិថុនា.....ឆ្នាំ...២០១៨.

# អង្គការលេខនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម



ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក
ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៨

# អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

